# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាអាជ្ញាកណ្តាល**
**THE ARBITRATION COUNCIL**

លេខ និង ឈ្មោះសំណុំរឿង ៖ ០៨៦/១៩ - យែនដើរេន អ៊ីភើរីល (ខេមបូឌា)
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩
យោបល់ជំទាស់ទៅនឹងសេចក្តីបង្គាប់ ៖ ដោយអាជ្ញាកណ្តាល អ៊ឹង សុទ្ធី

# សេចក្តីបង្គាប់អាជ្ញាកណ្តាល
(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ឡូន ស៊ីផាន់**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ
### ១- ភាគីនិយោជក
ឈ្មោះ ៖ **ក្រុមហ៊ុន យែនដើរេន អ៊ីភើរីល (ខេមបូឌា)**
អាសយដ្ឋាន ៖ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១២ ៦២៦ ៨៦៨ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ៖

១- លោក ហំ ភា — មេធាវី
២- លោកស្រី កែវ មាសចរិយា — ជំនួយការផ្នែកធនធានមនុស្ស

### ២- ភាគីកម្មករនិយោជិត
ឈ្មោះ ៖ **អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន យែនដើរេន អ៊ីភើរីល (ខេមបូឌា)**
អាសយដ្ឋាន៖ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១៦ ៦៩០ ៨៦៨/០៦៩ ៩៩៩ ២៩០ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

១- លោក ស៊ុំ វ៉ាន់ធា — មន្ត្រីច្បាប់សម្ព័ន្ធសហជីពស៊ីខៅឌូ
២- លោកស្រី ឃួន សុខា — កម្មករនីកាត់ព្រុយ
៣- លោកស្រី ណុន រី៉ា — កម្មករនីកាត់ព្រុយ

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

៤- លោកស្រី សាន់ ណាង កម្មការិនីកាត់ដេរ

៥- លោកស្រី ម៉ន សារឿន កម្មការិនីកាត់ព្រុយ

៦- លោកស្រី សន សំណាង កម្មការិនីកាត់ព្រុយ

៧- លោកស្រី ម៉ៅ ណាង កម្មការិនីកាត់ព្រុយ

## បញ្ហាវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- (ចំណុចទាមទារទី៥) កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់លើកទឹកចិត្ត និងប្រាក់រង្វាន់ ជូនកម្មករផ្នែកដេរ ដែលបន្ថែមការងារកាត់ព្រុយ។ ដោយឡែក ភាគីក្រុមហ៊ុនបញ្ជាក់ថា មិនអាចផ្តល់ជូនបានទេ។

២- (ចំណុចទាមទារទី៦) កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ប្រាក់ថ្លៃបាយធ្វើការថែមម៉ោងចំនួន ២០០០ រៀល (ពីរពាន់រៀល) ក្នុងមួយម៉ោង។ ដោយឡែក ភាគីក្រុមហ៊ុនបញ្ជាក់ថា មិនមានលទ្ធភាពផ្តល់ជូនទេ ដោយក្រុមហ៊ុនផ្តល់ជូនម្តង ២០០០ រៀល (ពីរពាន់រៀល) តាមប្រកាសរបស់ក្រសួង។

៣- (ចំណុចទាមទារទី៧) កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនបូកបញ្ចូលប្រាក់រង្វាន់អតីតភាពការងារទៅក្នុងប្រាក់ឈ្នួលគោល ដូចក្រុមជាងម៉ាស៊ីន ប្រធានផ្នែកដេរ និងបុគ្គលិកផ្សេងៗ។ ដោយឡែក ភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនមិនអាចផ្តល់ជូនបានទេ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨១ ក.ប/ប្រ.ក.រ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ (អាណត្តិទី១៧)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ឃែនជើរេន អ៊ីកែវីល (ខេមបូឌា) លេខ ៩៣៣ ក.ប/អក/វក ចុះថ្ងៃពុធ ១៣កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃ ទី២៨ ខែសីហា ឆ្នាំ២០១៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩។

**សវនាការ និង សង្ខេបនីតិវិធី**

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យ[illegible], សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃព្រហស្បតិ៍ ៧កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ត្រូវនឹងថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិត នៃក្រុមហ៊ុន យែនធើរេន អឹភីកែវីល (ខេមបូឌា) ស្តីពីការស្នើសុំជួយដោះស្រាយនូវលក្ខខណ្ឌការងារចំនួន ៨ ចំណុច ឱ្យបានល្អប្រសើរ។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញឱ្យដោះស្រាយវិវាទការងារនេះតាមនីតិវិធីច្បាប់ និងផ្សះផ្សា នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ៥ចំណុច និងមិនសះជានឹងគ្នា ចំនួន ៣ ចំណុច។ ហេតុនេះ ចំណុចមិនសះជាចំនួន ៣ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន យែនធើរេន អឹមផៃវីល (ខេមបូឌា) លេខ ៩៣៣ ក.ប/អក/វក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ ២០១៩។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សាលើករណីមិនសះជាចំនួន ៣ ចំណុច នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។ នៅថ្ងៃសវនាការ ភាគីទាំងពីរមានវត្តមាន តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

ភាគីទាំងពីរឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ២០១៩ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី២ ខែតុលា ឆ្នាំ២០១៩ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ របស់ក្រុមហ៊ុន យែនធើរេន អឹកែវីល (ខេមបូឌា) ប្រគល់សិទ្ធិជូន លោកមេធាវី ហំ ភា ឱ្យធ្វើជាអ្នកតំណាងដោយអាណត្តិរបស់ក្រុមហ៊ុន យែនធើរេន អឹកែវីល (ខេមបូឌា)។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន យែនធើរេន អឹកែវីល (ខេមបូឌា) ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩។

THE ARBITRATION COUNCIL

៣- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន ឃែនជើរេន អ៊ីកែរឺល (ខេមបូឌា) លេខ MOC-១៣៨៦០៩៥៩ ពណ.ចបព ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៣។

៤- លក្ខន្តិកៈក្រុមហ៊ុន ឃែនជើរេន អ៊ីកែរឺល (ខេមបូឌា) បានចុះទិដ្ឋាការនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម លេខ ១០៥/២០០៣ ពណ.ចបព ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៣។

៥- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ឃែនជើរេន អ៊ីកែរឺល (ខេមបូឌា) ចុះទិដ្ឋាការលេខ ៣៨១ កប.អក.អធក ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៥ ដោយប្រធាននាយកដ្ឋានអធិការកិច្ចការងារ។

៦- បញ្ជីប្រាក់ខែរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ឃែនជើរេន អ៊ីកែរឺល (ខេមបូឌា)។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតលេខ ០៣១/១៩ វិវាទ ចុះថ្ងៃទៅ០៣ ខែកញ្ញា ឆ្នាំ២០១៩ របស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ចាត់តាំងលោក ស៊ាង យ៉ូត និង លោក ស៊ុី វ៉ាន់ធា ដើម្បីអមសម្របសម្រួលលើករណីដោះស្រាយវិវាទក្រុមហ៊ុន ឃែនជើរេន អ៊ីកែរឺល (ខេមបូឌា)។

២- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ សហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ឃែនជើរេន អ៊ីកែរឺល (ខេមបូឌា) លេខ ១០៧ កប/បវក ចុះថ្ងៃព្រហស្បតិ៍ ១៥កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ពស ២៥៦១ ត្រូវនឹងថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨។

៣- លិខិតលេខ ០៦៩/១៨ ក.ប/វ.ក ចុះថ្ងៃព្រហស្បតិ៍ ១៥កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ពស ២៥៦១ ត្រូវនឹងថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ឃែនជើរេន អ៊ីកែរឺល (ខេមបូឌា) ជាអង្គការវិជ្ជាជីវៈមួយបានចុះបញ្ជីនៅនាយកដ្ឋានវិវាទការងារ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់។

៤- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន ឃែនជើរេន អ៊ីកែរឺល (ខេមបូឌា) ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩។

៥- ពាក្យបណ្តឹងរបស់តំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងារ នៃក្រុមហ៊ុន ឃែនជើរេន អ៊ីកែរឺល (ខេមបូឌា) គោរពជូន ប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីស្នើជួយអន្តរាគមឱ្យនិយោជកដោះស្រាយនូវការទាមទាររបស់កម្មករនិយោជិត ចុះថ្ងៃពុធ ៧កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ពស២៥៦៣ ត្រូវនឹងថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩។

៦- ញត្តិទាមទារ និងចាត់អ្នកតំណាង របស់កម្មករនិយោជិតនៃក្រុមហ៊ុនកាត់ដេរ ឃែនជើរេន អ៊ីកែរឺល (ខេមបូឌា) ចុះថ្ងៃពុធ ១៥ រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩។

៧- លិខិតលេខ ០៣៣/១៩ សបក/វិវាទ ចុះថ្ងៃព្រហស្បតិ៍ ៧កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៩ របស់របស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីជូនសារណាសង្ខេបសំណុំរឿងលេខ ០៨៦/១៩-ឃែនជើរេន អ៊ីកែរឺល (ខេមបូឌា)។

៨- កាត និងបង្កាន់ដៃបើកប្រាក់ខែរបស់កម្មករនិយោជិត។

THE ARBITRATION COUNCIL

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ឃែនជើរេន អ៊ីកែវីល (ខេមបូឌា) លេខ ៩៣៣ ក.ប/អក/វក ចុះថ្ងៃពុធ ១៣រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ឃែនជើរេន អ៊ីកែវីល (ខេមបូឌា) ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០១៩។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ឃែនជើរេន អ៊ីកែវីល (ខេមបូឌា) លេខ ០១៣ កប/អក/វក/កវក៤ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០១៩ របស់នាយកដ្ឋានវិវាទការងារ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៤៦៨ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ១កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៤៦៩ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ១កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

ក្រុមហ៊ុន ឃែនជើរេន អ៊ីកែវីល (ខេមបូឌា) គឺជាក្រុមហ៊ុនដែលមានសកម្មភាពចម្បងក្នុងការកាត់ដេរសម្លៀកបំពាក់ និងមានជួលកម្មករនិយោជិតសរុប ចំនួន ១០២០ នាក់ *(យោងតាមរបាយការណ៍មិនសះជា លេខ ៩៣៣ ក.ប/អក/វក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩ របស់នាយកដ្ឋានវិវាទការងារ)*។

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត និងប្រាក់រង្វាន់ជូនកម្មករនិយោជិតផ្នែកដេរ ដែលបន្ថែមការងារកាត់ព្រុយ**

- ភាគីកម្មករនិយោជិតបានបញ្ជាក់ការទាមទារឱ្យនិយោជកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តចំនួន ២០ ដុល្លារអាមេរិក ក្នុងមួយខែ នៅពេលដេរ និងកាត់ព្រុយគ្រប់ចំនួនកំណត់ និងផ្តល់ប្រាក់រង្វាន់ចំនួន ២០ ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់ការបន្ថែមការងារកាត់ព្រុយ ជូនកម្មករនិយោជិតផ្នែកដេរ។
- ភាគីកម្មករនិយោជិតបញ្ជាក់ពីមូលហេតុនៃទាមទារថា៖
    - នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៩ និយោជកបានបន្ថែមការងារកាត់ព្រុយឱ្យកម្មករនិយោជិតផ្នែកដេរធ្វើវិញ។ កម្មករនិយោជិតផ្នែកដេរ ត្រូវដេរផង និងកាត់ព្រុយឱ្យស្អាត មុនពេលបញ្ជូនទៅផ្នែក QC តែម្តង។
    - ការបន្ថែមការងារកាត់ព្រុយធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍កម្មករនិយោជិតក្រុមដេរ ព្រោះពីមុនក្រុមដេរ ដេរស៊ីប៊ុងបានគ្រប់ចំនួន ទទួលបានប្រាក់រង្វាន់ពី ៣០ ដុល្លារអាមេរិក ទៅ ៤០

ដុល្លារអាមេរិក បន្ថែមក្នុងមួយខែ ប៉ុន្តែ តាំងពីនិយោជកបន្ថែមការងារកាត់ព្រុយ ធ្វើឱ្យកម្មករនិយោជិតក្រុមដេរ ដេរមិនបានគ្រប់ចំនួនបុង បាត់បង់អត្ថប្រយោជន៍ដែលពួកគាត់ធ្លាប់ទទួលបានកន្លងមក។ បើទោះជា និយោជកបានបន្ថយចំនួនកំណត់ក៏ដោយ ក៏កម្មករនិយោជិតក៏នៅតែធ្វើមិនបានគ្រប់ចំនួនទេ ឧទាហរណ៍ ពីមុននិយោជកកំណត់ចំនួនដេរ ៥០ អាវ ក្នុងមួយម៉ោង ក្រោយមកបន្ថយចំនួន ៤០ អាវ ក្នុងមួយម៉ោង។

- កម្មករនិយោជិតក្រុមទី៧ ផ្នែកដេរជើងខោ ម្នាក់បានលើកឡើងក្នុងសវនាការថា កម្មករនិយោជិតម្នាក់ត្រូវដេរផង និងកាត់ព្រុយផង បណ្តាលឱ្យដេរមិនបានគ្រប់ចំនួនកំណត់ បាត់បង់អត្ថប្រយោជន៍។
- ការអនុវត្តរបស់និយោជកមិនត្រឹមត្រូវតាមមាត្រា ៦៥ នៃច្បាប់ស្តីពីការងារ, បានន័យថា កម្មករនិយោជិត និងនិយោជក មិនត្រូវអនុវត្តផ្ទុយពី ខ ចែង ក្នុងកិច្ចសន្យាទេ។ មាត្រា ៦៩ កម្មករនិយោជិតមានកាតព្វកិច្ចអនុវត្តតែសកម្មភាពការងារតាមកិច្ចសន្យា បានន័យថា កម្មករនិយោជិតផ្នែកដេរ ធ្វើការតាមផ្នែកដេរ មិនត្រូវបន្ថែមការងារផ្ទុយពីកិច្ចព្រមព្រៀងក្នុងកិច្ចសន្យាឡើយ។
- ដូច្នេះ និយោជកត្រូវតែផ្តល់ប្រាក់រង្វាន់ ចំនួន ២០ ដុល្លារអាមេរិក ចំពោះការបន្ថែមការងារកាត់ព្រុយ ឱ្យកម្មករនិយោជិតផ្នែកដេរ។

- ភាគីនិយោជកបានបង្ហាញថា មិនអាចផ្តល់ជូនតាមការទាមទាររបស់កម្មករនិយោជិតទេ ព្រោះការធ្វើបែបនេះ គឺបន្ថែមការចំណាយរបស់និយោជក។
- ភាគីនិយោជកបានបញ្ជាក់មូលហេតុថា៖
  - មាត្រា ៦៩ នៃច្បាប់ស្តីពីការងារ គ្រាន់តែកំណត់ក្របខណ្ឌការងារនៃកិច្ចសន្យាការងារ កម្មករនិយោជិតត្រូវបញ្ចេញគ្រប់សកម្មភាពវិជ្ជាជីវៈរបស់ខ្លួនដល់សហគ្រាស អត់មានកំណត់ឱ្យនិយោជកបន្ថែមប្រាក់រង្វាន់អ្វីទេ។
  - និយោជកមិនបានបន្ថែមការងារផ្ទុយពីច្បាប់ដូចភាគីកម្មករនិយោជិតលើកឡើងទេ។ ជាធម្មតាកម្មករនិយោជិតផ្នែកដេរ ឬផុង តែងតែមានព្រុយរាងវែង ផ្នែកដេរគ្រាន់តែជួយកាត់ខ្លះៗ បញ្ជូនទៅឱ្យផ្នែកកាត់ព្រុយ កាត់ព្រុយដដែលទេ។ កម្មករនិយោជិតក្រុមទី៧ នៅកន្លែងប្រាយម៉ា មិនសូវមានព្រុយកាត់ទេ។
  - ម៉្យាង និយោជកបានបន្ថយចំនួនដេរតិចជាងមុន។ និយោជកនៅតែផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តជូនកម្មករនិយោជិត នៅពេលដែលដេរ និងកាត់ព្រុយបានគ្រប់ចំនួនកំណត់។

ក្រោយពីបានពិនិត្យភស្តុតាងដែលភាគីដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ប្រាក់ឈ្នួលកម្មករនិយោជិតផ្នែកដេរមុនពេលរំសាយក្រុមកាត់ព្រុយ និង ក្រោយរំសាយ ប្រាក់ឈ្នួលកម្មករនិយោជិតមិនមានចំនួនថយចុះទេ។

**ចំណុចវិវាទទី ២ ៖** ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ចំនួន ២០០០ រៀល ក្នុងមួយម៉ោង

- ភាគីទាំងពីរបានទទួលស្គាល់ថា និយោជកបានផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ចាប់ពីម៉ោង៤ ដល់ ៦ ល្ងាច ចំនួន ២០០០ រៀល ក្នុងមួយថ្ងៃ។

THE ARBITRATION COUNCIL

- ភាគីកម្មករនិយោជិត បានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - ០ កម្មករនិយោជិតត្រូវការចំណាយច្រើន ទៅលើការទិញអាហារ។
  - ០ ការផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ២០០០ រៀល ក្នុងមួយម៉ោង ជូនកម្មករនិយោជិត ដើម្បីឱ្យកម្មករនិយោជិតអាចហូបអាហាបានគ្រប់គ្រាន់ មានកម្លាំងធ្វើការបន្ថែមម៉ោង។
- ភាគីនិយោជកបានលើកឡើងថា និយោជកមិនអាចផ្តល់ជូនតាមការទាមទាររបស់កម្មករនិយោជិតបានទេ ព្រោះនិយោជកបានផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ២០០០ រៀល ក្នុងមួយថ្ងៃ តាមច្បាប់ រួចហើយ។

**ចំណុចវិវាទទី ៣ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបូកប្រាក់រង្វាន់អតីតភាពការងារ ជាមួយប្រាក់ឈ្នួលគោល ដូចខាងរដ្ឋបាល ប្រធានផ្នែកដេរ និងក្រុមជាងម៉ាស៊ីន**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារឱ្យនិយោជកបូកប្រាក់រង្វាន់អតីតភាពការងារជាមួយប្រាក់ឈ្នួលគោល សម្រាប់ជាមូលដ្ឋានគណនាប្រាក់ឈ្នួលបន្ថែមម៉ោង។
- ភាគីកម្មករនិយោជិតលើកហេតុផលថា៖
  - ០ និយោជកបានបញ្ចូលប្រាក់រង្វាន់អតីតភាពការងារ ជាមួយប្រាក់ឈ្នួលគោលសម្រាប់ជាមូលដ្ឋានគណនាប្រាក់ឈ្នួលបន្ថែមម៉ោង ជូនកម្មករនិយោជិតផ្នែករដ្ឋបាល ប្រធានផ្នែក និងជាងម៉ាស៊ីន។
  - ០ និយោជកមានការរើសអើងកម្មករនិយោជិត ព្រោះនិយោជកផ្តល់ផលប្រយោជន៍ខុសគ្នាជូនកម្មករនិយោជិតម្នាក់ៗ។
- ភាគីនិយោជកជំទាស់នឹងការលើកឡើងរបស់កម្មករនិយោជិតដែលថា និយោជកបានបញ្ចូលប្រាក់រង្វាន់អតីតភាពការងារទៅក្នុងប្រាក់ឈ្នួលគោល ជាមូលដ្ឋានគណនាប្រាក់ឈ្នួលបន្ថែមម៉ោង ជូនកម្មករនិយោជិតផ្នែករដ្ឋបាល ប្រធានផ្នែក និងជាងម៉ាស៊ីន ទេ។
- ករណីនេះ គឺជាសិទ្ធិតាមច្បាប់ ដែលទុកឱ្យនិយោជកគណនាទៅតាមច្បាប់ ត្រូវបែងចែកឱ្យដាច់ទៅតាមលំដាប់ប្រាក់បំណាច់អតីតភាពការងារ ប្រាក់រង្វាន់ ប្រាក់លើកទឹកចិត្តផ្សេងៗ ត្រូវដាក់តាមលំដាប់ ដើម្បីជាភស្តុតាង នៅពេលខាងក្រសួង ឬអង្គការអោយឡូ ត្រួតពិនិត្យ បើសិនបញ្ចូលតែម្តង ធ្វើឱ្យបាត់ទិន្នន័យ ក្រុមហ៊ុនអាចមានបញ្ហាចំពោះមុខក្រសួងការងារ។

## ហេតុផលនៃសេចក្តីសម្រេច ៖

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់រង្វាន់ចំនួន ២០ ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់ការបន្ថែមការងារកាត់ព្រុយ ជូនកម្មករនិយោជិតផ្នែកដេរ**

ក្នុងសវនាការភាគីកម្មករនិយោជិតបានបញ្ជាក់ការទាមទារ ឱ្យនិយោជកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តចំនួន ២០ ដុល្លារអាមេរិក ក្នុងមួយខែ នៅពេលដេរ និងកាត់ព្រុយដល់គោលដៅកំណត់ និងប្រាក់រង្វាន់ចំនួន ២០ ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់ការបន្ថែមការងារកាត់ព្រុយ ជូនកម្មករនិយោជិតផ្នែកដេរ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចផ្តល់ប្រាក់រង្វាន់តាមការទាមទាររបស់កម្មករនិយោជិតផ្នែកដេរ ដែរឬទេ ?

THE ARBITRATION COUNCIL

មាត្រា ២ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា៖ *"...សហគ្រាសនីមួយៗ អាចមានគ្រឹះស្ថានច្រើន ហើយគ្រឹះស្ថាននីមួយៗនោះ មានប្រើមនុស្សមួយក្រុមធ្វើការរួមគ្នាក្នុងទីកន្លែងណាមួយជាប្រាកដ ដូចជាក្នុងរោងចក្រ រោងជាង ការដ្ឋាន។ល។ ក្រោមការគ្រប់គ្រង និង ដឹកនាំនៃនិយោជក..."*។

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា ២ នៃច្បាប់ស្តីពីការងារខាងលើ មានន័យថា និយោជកមានសិទ្ធិចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុន ដរាបណាសិទ្ធិនេះ ត្រូវបានធ្វើឡើងដោយស្របច្បាប់ និងមានលក្ខណៈសមរម្យ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៦២/០៦-ឃ្វីកស៊ូ ហេតុផលនៃចំណុចវិវាទទី៥, លេខ ១០៨/០៦-ទ្រីនុងហ្គាល គូម៉ាក់, លេខ ៣៣/០៧-ហ្គោលហ្វេម ហេតុផលនៃចំណុចវិវាទទី៣ និងលេខ ១១៩/០៩-អេស អិល ហេតុផលនៃចំណុចវិវាទទី ៤និង៥)*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ។

នៅក្នុង*សេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ២៤/០៥-វ៉ារ វែល ហេតុផលចំណុចវិវាទទី២* ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចថា " *និយោជកតាមរយៈការសំរេចជាឯកតោភាគី អាចរៀបចំផែនការផ្តល់ប្រាក់រង្វាន់ផ្សេងៗក្រៅពីប្រាក់រង្វាន់ដែលកំណត់ក្នុងច្បាប់ការងារ ដើម្បីជំរុញ ឬលើកទឹកចិត្តកម្មករនិយោជិតខិតខំធ្វើឱ្យមានផលិតកម្មច្រើន ហើយប្រើពេលវេលាតិច។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការកំណត់ផ្តល់ប្រាក់រង្វាន់នេះ មិនមានលក្ខណៈផ្ទុយនឹងច្បាប់ការងារ ហើយផែនការផ្តល់ប្រាក់រង្វាន់របស់និយោជក ក៏មិនបានបំពាននឹងសិទ្ធិណាមួយរបស់កម្មករនិយោជិតឡើយ*"។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្រប និងទទួលយកការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់កម្មករនិយោជិតផ្នែកដេរ គឺជាប្រាក់រង្វាន់ដាច់ដោយឡែកពីប្រាក់ឈ្នួលគោលរបស់ពួកគាត់។ ដោយហេតុថា ប្រាក់រង្វាន់លើកទឹកចិត្តនេះ ជាប្រាក់រង្វាន់ដែលមិនមានចែងក្នុងច្បាប់ស្តីពីការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានសិទ្ធិចាត់ចែង ដើម្បីកំណត់លក្ខខណ្ឌក្នុងការផ្តល់ប្រាក់រង្វាន់ទាំងនេះ ជូនកម្មករនិយោជិត។ ចំពោះការបន្ថែមការងារកាត់ព្រុយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីកម្មករនិយោជិតមិនបានជំទាស់នឹងការបន្ថែមការងារនេះទេ ដោយបានអះអាងថា បាត់បង់អត្ថប្រយោជន៍ដែលធ្លាប់បានទទួល ប៉ុន្តែពួកគាត់មិនបានដាក់ភស្តុតាងបញ្ជាក់ពីការបាត់បង់អត្ថប្រយោជន៍ ដូចដែលបានលើកឡើងនោះទេ។ សម្រាប់ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មិនមានបទបញ្ញត្តិណាមួយបញ្ជាក់ពីកាតព្វកិច្ចរបស់និយោជកឱ្យបន្ថែមប្រាក់រង្វាន់នេះទេ ដោយឡែក ភាគីទាំងពីរអាចចរចាបន្ថែមបាន។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមិនមានកាតព្វកិច្ចផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តចំនួន ២០ ដុល្លារអាមេរិក ក្នុងមួយខែ នៅពេលកម្មករនិយោជិតដេរ និងកាត់ព្រុយគ្រប់ចំនួនកំណត់ និងផ្តល់ប្រាក់រង្វាន់ចំនួន ២០ ដុល្លារអាមេរិក សម្រាប់ការបន្ថែមការងារកាត់ព្រុយ ជូនកម្មករនិយោជិតផ្នែកដេរទេ។

**ចំណុចវិវាទទី ២ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ចំនួន ២០០០ រៀល ក្នុងមួយម៉ោង**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ចំនួន ២០០០ រៀល ក្នុងមួយម៉ោង ដែរឬទេ?

ចំណុចទី២ នៃសេចក្តីជូនដំណឹងលេខ ០៤១/១១ កប/ស.ជ.ណ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១១ ចែងថា ៖ "*កម្មករនិយោជិត ដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោង តាមសំណូមពររបស់និយោជក ត្រូវទទួលបានប្រាក់ថ្លៃបាយ ចំនួន ២០០០ (ពីរពាន់) រៀល ក្នុងមួយថ្ងៃ ឬទទួលបានការផ្តល់ជូនបាយមួយពេលដោយឥតគិតថ្លៃ។*" ។

*នៅក្នុងសំណុំរឿងនេះ* ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា *និយោជកបានផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ២០០០ រៀល ក្នុងមួយថ្ងៃ ស្របតាមសេចក្តីជូនដំណឹងលេខ* ០៤១/១១ កប/ស.ជ.ណ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មិនមានបទប្បញ្ញត្តិច្បាប់ការងារ អនុសញ្ញារួម ឬកិច្ចព្រមព្រៀងណាមួយរវាងភាគីទាំងពីរ ឬបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ឬការអនុវត្តកន្លងមក ដែលកំណត់អំពីកាតព្វកិច្ចរបស់និយោជកក្នុងការផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ២០០០ រៀល ក្នុងមួយម៉ោង ជូនកម្មករនិយោជិត នោះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទាររបស់ភាគីកម្មករនិយោជិតមានលក្ខណៈប្រសើរជាងច្បាប់កំណត់ ដែលចំណុចវិវាទនេះ គឺជាវិវាទអំពីផលប្រយោជន៍។

ចំពោះវិវាទអំពីផលប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណា ដូចខាងក្រោម ៖

កថាខណ្ឌទី២ នៃមាត្រា ៩៦ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា ៖ "*អនុសញ្ញារួម គឺជាកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដែលទាក់ទងដល់បទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងមាត្រា ៩៦ កថាខណ្ឌទី១ អនុសញ្ញារួម ត្រូវធ្វើឡើងដោយព្រមព្រៀងគ្នារវាង ៖*

*ក. មួយចំណែក គឺនិយោជកម្នាក់ និយោជកមួយក្រុម ឬអង្គការមួយ ឬអង្គការ ច្រើនតំណាងឱ្យនិយោជក។*

*ខ. មួយចំណែកទៀត គឺអង្គការសហជីពមួយ ឬអង្គការសហជីពច្រើនតំណាងឱ្យកម្មករនិយោជិត។ ...។*"

មាត្រា ៥៤ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ចែងថា៖ "*ភាពជាតំណាងបំផុតនៃសហជីពត្រូវបានទទួលស្គាល់នៅក្នុងក្របខ័ណ្ឌនៃសហគ្រាស ឬគ្រឹះស្ថាន។ សម្រាប់គោលបំណងនៃការចរចាអនុសញ្ញារួម ឬដោះស្រាយវិវាទការងាររួម គឺសហជីពដែលមានភាពជាតំណាងបំផុតទទួលបានសិទ្ធិផ្តាច់មុខ។*

*សហជីពមួយនឹងទទួលបានភាពជាតំណាងបំផុត លុះត្រាតែ សហជីពនោះបានបំពេញគ្រប់លក្ខណវិនិច្ឆ័យ ដូចតទៅ ៖*

*...*

*គ- មានសមាជិកដែលមានបណ្ណសម្គាល់ និងបញ្ជីឈ្មោះសមាជិកត្រឹមត្រូវច្រើនជាងគេ ឬទទួលបានការបោះឆ្នោតគាំទ្រច្រើនជាងគេនៅក្នុងសហគ្រាស ឬគ្រឹះស្ថានមួយ ដូចករណីខាងក្រោម ៖*

*- សហជីពដែលមានសមាជិកចាប់ពី ៣០% (សាមសិបភាគរយ) នៃចំនួនកម្មករនិយោជិតសរុប នៅក្នុងសហគ្រាស ឬគ្រឹះស្ថានដែលមានសហជីពតែមួយ ឬ*

*- សហជីពណាដែលស្វែងរកបានសំឡេងគាំទ្រពីកម្មករនិយោជិតច្រើនជាងគេបំផុត ដោយលើសពី ៣០% (សាមសិបភាគរយ) នៃចំនួនកម្មករនិយោជិតសរុបក្នុងសហគ្រាស ឬគ្រឹះស្ថានដែលមានសហជីពលើសពី ១ (មួយ) ឬ*

THE ARBITRATION COUNCIL

*- ក្នុងករណីសហជីពណាមួយពុំអាចរកសមាជិកគាំទ្របាន ចាប់ពី ៣០% (សាមសិបភាគរយ) នៃចំនួនកម្មករនិយោជិតសរុប ត្រូវរៀបចំការបោះឆ្នោតស្វែងរកការគាំទ្រ ឱ្យបានសំឡេងច្រើនជាងគេបំផុត លើសពី ៣០% (សាមសិបភាគរយ) នៃចំនួនកម្មករនិយោជិត សរុបក្នុងសហគ្រាស ឬ គ្រឹះស្ថាននោះ។ ...។*

*ប្រសិនបើនៅក្នុងសហគ្រាស ឬគ្រឹះស្ថានមួយមានសហជីពមូលដ្ឋានច្រើនផ្សេងៗគ្នា មិនអាចបំពេញគ្រប់លក្ខណវិនិច្ឆ័យ ដូចមានចែងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ ហើយពុំអាចស្វែងរកការទទួលស្គាល់ ភាពជាតំណាងបំផុតទេ ការចរចាចុះអនុសញ្ញារួមត្រូវតែអនុវត្តដាច់ខាតតាមមាត្រា ៧២ (ក្រុមប្រឹក្សាចរចា) នៃច្បាប់នេះ។"* ។

មាត្រា ៧២ នៃច្បាប់ស្តីពីសហជីព ខាងលើដដែល ចែងថា៖ "*ក្រុមប្រឹក្សាចរចានៃសហជីព និងនិយោជកដែលត្រូវបានបង្កើតឡើង មានសិទ្ធិពេញលេញក្នុងនាមកម្មករនិយោជិតទាំងអស់ ឬនិយោជក ទាំងអស់នៅគ្រប់កម្រិតថ្នាក់ចរចាក្នុងករណីដែលត្រូវមានការចរចា ចុះអនុសញ្ញារួមរវាងនិយោជកមួយ និងសហជីពច្រើនដែលគ្មានភាពជាតំណាងបំផុត ឬរវាងនិយោជកច្រើន និងសហជីពច្រើនដែលគ្មានភាពជាតំណាងបំផុត។*" ។

យោងតាមកថាខណ្ឌទី២ មាត្រា ៩៦ នៃច្បាប់ស្តីពីការងារ, មាត្រា ៥៤ និងមាត្រា ៧២ នៃច្បាប់ស្តីពីសហជីពខាងលើ ចំពោះវិវាទទាក់ទងនឹងផលប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើភាពជាតំណាងបំផុតរបស់សហជីពដែលជាភាគីវិវាទ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាពជាតំណាងបំផុតរបស់សហជីព ផ្តល់សិទ្ធិតាមផ្លូវច្បាប់ដល់សហជីពនេះ ក្នុងការចរចាបង្កើតអនុសញ្ញារួមក្នុងក្រុមហ៊ុន និងមានសិទ្ធិស្របច្បាប់ក្នុងការនាំសំណុំរឿងពាក់ព័ន្ធនឹងវិវាទអំពីផលប្រយោជន៍ មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការដោះស្រាយ។

កថាខណ្ឌទី១ នៃប្រការ ៤៣ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា ៖ "*សេចក្តីបង្គាប់អាជ្ញាកណ្តាលដែលដោះស្រាយវិវាទផលប្រយោជន៍ នឹងត្រូវមកជំនួសអនុសញ្ញារួម និងមានប្រសិទ្ធភាពអនុវត្តរយៈពេលមួយឆ្នាំ ចាប់តាំងពីថ្ងៃចូលជាស្ថាពរ លើកលែងតែភាគីវិវាទបានព្រមព្រៀងគ្នាលើការធ្វើអនុសញ្ញារួមថ្មីមួយ ដើម្បីដាក់ជំនួសសេចក្តីបង្គាប់នោះ។*" ។

យោងតាមខ្លឹមសារនៃកថាខណ្ឌទី១ នៃប្រការ ៤៣ នៃប្រកាស ០៩៩ សកបយ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើវិវាទអំពីផលប្រយោជន៍ នឹងក្លាយជាអនុសញ្ញារួម ដែលអនុវត្តទៅលើកម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុន ហើយធ្វើឱ្យកម្មករនិយោជិតទាំងអស់បាត់បង់សិទ្ធិក្នុងការចរចាអនុសញ្ញារួម និងសិទ្ធិក្នុងការធ្វើកូដកម្ម ដើម្បីទាមទារលើវិវាទ ដែលទាក់ទងនឹងផលប្រយោជន៍នាពេលអនាគត។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចធ្វើការដោះស្រាយវិវាទអំពីផលប្រយោជន៍បាន លុះត្រាតែសហជីពដែលទាមទារនាំយកវិវាទនោះមក ជាសហជីពដែលមានភាពជាតំណាងបំផុតនៅក្នុងសហគ្រាស ឬសហជីពមូលដ្ឋានច្រើនផ្សេងគ្នា ដែលមានសិទ្ធិក្នុងការចរចាចុះអនុសញ្ញារួម ស្របតាមមាត្រា ៥៤ និងមាត្រា ៧២ នៃច្បាប់ស្តីពីសហជីពខាងលើ។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាវិវាទអំពីផលប្រយោជន៍ ប្រសិនបើសហជីពដែលនាំវិវាទការងារនោះមក ជាសហជីពដែលមិនមានភាពតំណាងបំផុត នៅ

ក្នុងក្រុមហ៊ុន។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៨១/០៤-អេហ្វ៊ើហ្គីន ហេតុផលនៃចំណុចវិវាទទី៤, លេខ ៩៨/០៤-ហ្វេតយូនៀន ហេតុផលនៃចំណុចវិវាទទី៣, លេខ ០២/១១-ពូ យៀន ហេតុផលនៃចំណុចវិវាទទី២, លេខ ៦៦/១១-អ៊ិន ហាន ស៊ុង ហេតុផលនៃចំណុចវិវាទទី១, លេខ ១១៨/១៦-អ៊ី-ចេង (ខេមបូឌា) ឧបកើរសេិន ហេតុផលនៃចំណុចវិវាទទី៧ និង លេខ ២០៣/១៦-អ៊ិនយ៉ុង វ៉ុនដាង អ៊ីកែវិល ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី៤)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើនេះដែរ។

នៅក្នុងសំណុំរឿងនេះ កម្មករនិយោជិតដែលជាភាគីដើមបណ្តឹង មិនមែនជាសហជីពដែលមានភាពជាតំណាងបំផុត ឬ ជាសហជីពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ស្របតាមលក្ខខណ្ឌ ដែលមានចែងនៅក្នុងច្បាប់ស្តីពីសហជីព ក្នុងការនាំវិវាទដែលទាក់ទងនឹងផលប្រយោជន៍ មកក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីធ្វើការពិចារណានោះឡើយ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនពិចារណាលើការទាមទាររបស់ភាគីកម្មករនិយោជិតទេ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ២០០០ រៀល ក្នុងមួយម៉ោង។

**ចំណុចវិវាទទី ៣៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបញ្ចូលប្រាក់រង្វាន់អតីតភាពការងារ សម្រាប់ជាមូលដ្ឋានគណនាប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោង**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចបូកប្រាក់រង្វាន់អតីតភាពការងារសម្រាប់ជាមូលដ្ឋានគណនាប្រាក់ឈ្នួលបធ្វើការបន្ថែមម៉ោង ជូនកម្មករនិយោជិត ដែរឬទេ?

មាត្រា ១៣៩ (ថ្មី) នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣៩ និងមាត្រា ១៤៤ នៃច្បាប់ស្តីពីការងារ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ចែងថា ៖ *"ក្នុងករណីមានកិច្ចការប្រញាប់ខុសធម្មតា តម្រូវឱ្យកម្មករនិយោជិតធ្វើការបន្ថែមក្រៅម៉ោងពេលធម្មតា ម៉ោងពេលបន្ថែមទាំងនេះ ត្រូវឱ្យឈ្នួលតាមអត្រាតម្លើង ៥០% (ហាសិបភាគរយ)។ ប្រសិនបើធ្វើការបន្ថែមម៉ោងនៅពេលយប់ចន្លោះពីម៉ោង ២២ ទៅម៉ោង ៥ ភ្លឺ ឬនៅក្នុងថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ ត្រូវផ្តល់ប្រាក់បន្ថែមតាមអត្រាតម្លើង ១០០ % (មួយរយភាគរយ)។"*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា ១៣៩ (ថ្មី) ខាងលើ មិនបានបញ្ជាក់ជាក់លាក់អំពីនិយមន័យនៃប្រាក់ឈ្នួលក្នុងពេលធ្វើការបន្ថែមម៉ោង សម្រាប់ការគណនាប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោង ថាតើត្រូវយកប្រាក់ឈ្នួលគោល មកធ្វើជាមូលដ្ឋាន ក្នុងការគណនា ឬយ៉ាងណានោះទេ។

ប្រការ ៥ នៃប្រកាសលេខ ៨០ សកបយ. ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៩៩ របស់ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ស្តីពីការធ្វើការបន្ថែមម៉ោង ក្រៅពីចិរវេលាធ្វើការធម្មតា ចែងថា ៖ *"ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវផ្តល់ប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោង ជូនកម្មករនិយោជិតដូចតទៅ ៖*

*ក-ស្មើនឹង ១៥០ ភាគរយ (ឬមួយដងកន្លះ) នៃប្រាក់ឈ្នួលពេលធ្វើការធម្មតា ចំពោះការធ្វើការបន្ថែមម៉ោងនៅពេលថ្ងៃនៃថ្ងៃធ្វើការធម្មតា។*

*ខ- ស្មើនឹង ២០០ ភាគរយ (ឬពីរដង) នៃប្រាក់ឈ្នួលពេលធ្វើការធម្មតា ចំពោះការធ្វើការបន្ថែមម៉ោងនៅពេលយប់ (ពីម៉ោង ២៖០០ ទៅម៉ោង ៥៖០០ ព្រឹក)។*

ផ្អែកលើខ្លឹមសារនៃប្រការ៥ នៃប្រកាសលេខ ៨០ សកបយ. ខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល យល់ឃើញថា ប្រកាសនេះ ក៏មិនបានកំណត់ច្បាស់ថា ការគិតប្រាក់ឈ្នួលក្នុងពេលធ្វើការបន្ថែមម៉ោង ត្រូវគិតតែប្រាក់ឈ្នួលគោល (ប្រាក់ឈ្នួលអប្បបរមា) ឬយ៉ាងណានោះដែរ។

ហេតុដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិចារណាថា តើ "ប្រាក់ឈ្នួលពេលធ្វើការធម្មតា" មានន័យដូចម្ដេច?

មាត្រា ១០២ នៃច្បាប់ស្ដីពីការងារ ចែងថា៖ *"តាមន័យនៃច្បាប់នេះ ពាក្យថា ប្រាក់ឈ្នួល ទោះបីការកំណត់ ឬរបៀបគិតយ៉ាងណាក៏ដោយ មានន័យថា ឈ្នួលការងារ ឬឈ្នួលសេវា ដែលអាចគិតជាប្រាក់បាន ឬ កំណត់បានដោយការព្រមព្រៀងគ្នា ឬដោយច្បាប់ជាតិ ហើយដែលនិយោជកត្រូវបើកឲកម្មករនិយោជិត តាមកិច្ចសន្យាជួលការងារ ឬសេវាដោយលាយលក្ខណ៍អក្សរ ឬដោយមាត់ទទេ ទោះចំពោះការងារដែលបានធ្វើក្ដី ឬដែលត្រូវធ្វើក្ដី ចំពោះសេវាដែលបានបំពេញ ឬត្រូវបំពេញក្ដី។"*

មាត្រា ១០៣ នៃច្បាប់ស្ដីពីការងារ ចែងថា៖ *"ប្រាក់ឈ្នួលមានជាអាទិ៍ដូចតទៅ ៖*

- *ប្រាក់ឈ្នួលសុទ្ធសាធ*
- *ប្រាក់ម៉ោងបន្ថែម*
- *កំរៃជើងសា*
- *បុព្វលាភ និងប្រាក់បំណាច់*
- *ភាគកម្មក្នុងប្រាក់ចំណេញ*
- *ប្រាក់ដែលបើកជាម្ហូបអាហារ...*"។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា មាត្រា ១០២ ពាក្យថា ប្រាក់ឈ្នួល គឺសំដៅតែទៅលើឈ្នួលការងារសុទ្ធសាធដែលនិយោជកត្រូវផ្ដល់ឱ្យកម្មករនិយោជិត ជាថ្នូរនឹងការងារដែលកម្មករនិយោជិតបានបំពេញជូននិយោជក។ ចំណែកឯប្រាក់ឈ្នួល នៅក្នុងមាត្រា ១០៣ គឺមានន័យទូលំទូលាយ ដែលសំដៅទៅលើចំណូលប្រចាំខែ ដែលកម្មករនិយោជិតទទួលបានពីការធ្វើការឱ្យនិយោជក ដែលចំណូលនេះ អាចមានច្រើនប្រភេទ រួមបញ្ចូលទាំងឈ្នួលការងារសុទ្ធសាធ និងអត្ថប្រយោជន៍ផ្សេងៗទៀត។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ប្រាក់ឈ្នួលពេលធ្វើការធម្មតា គឺជាប្រាក់ឈ្នួលដែលកំណត់នៅក្នុងមាត្រា ១០២ ដែលជាឈ្នួលការងារ នៅក្នុងសេចក្ដីបង្គាប់អាជ្ញាកណ្ដាលសំណុំរឿងលេខលេខ ៧៤/០៨-ជេនើរេសិន ហេតុផលចំណុចវិវាទទី១៣ បានបកស្រាយថា *"វចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឃរាជ ជួន ណាត ទំព័រ ៤៧៦ បានពន្យល់ពាក្យថា "ធម្មតា" មានន័យថា "ប្រក្រតី អ្វីៗ ដែលតែងមានមកជាទំនៀមទម្លាប់។ ដូចនេះពាក្យថា ""ប្រាក់ឈ្នួលពេលធ្វើការធម្មតា" មានន័យថា ជាប្រាក់ឈ្នួលដែលកម្មករនិយោជិតទទួលបានជាប្រក្រតីនៅពេលធ្វើការនៅក្នុងថ្ងៃធ្វើការធម្មតា។*

*[...] មានន័យថា វាមិនអាស្រ័យនៅលើការបំពេញការងារបានល្អ ឬមិនល្អរបស់កម្មករនិយោជិតនៅក្នុងខែណាមួយ ឬការសម្រេចបានតាមគោលដៅដែលកំណត់ដោយក្រុមហ៊ុននៅក្នុងខែណាមួយនោះឡើយ។ កម្មករនិយោជិតរំពឹងទុកជាមុនថា ខ្លួននឹងទទួលបានប្រាក់នេះនៅរៀងរាល់ខែ ហើយចាត់ទុកថា វាគឺជាផ្នែកមួយនៃកញ្ចប់អត្ថប្រយោជន៍ ដែលពួកគេត្រូវទទួលបានជាថ្នូរនឹងការងារនៅពេលធ្វើការឱ្យនិយោជក។"*។

ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ស្របនិងទទួលយកការបកស្រាយរបស់ក្រុមប្រឹក្សា-អាជ្ញាកណ្ដាលក្នុងសំណុំរឿងមុននេះដែរ។

THE ARBITRATION COUNCIL

ជាបន្ត ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា *"ប្រាក់ឈ្នួលពេលធ្វើការធម្មតា"* មានរួមបញ្ចូលប្រាក់រង្វាន់អតីតភាពការងារ មកធ្វើជាមូលដ្ឋាននៃការគណនាប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោងដែរ ឬទេ?

ចំណុចទី៣ នៃសេចក្តីជូនដំណឹងលេខ ០៤១/១១ កប/សជណ ចុះថ្ងៃទី០៧ ខែមិនា ឆ្នាំ២០១១ ចែងថា ៖ *"ក.កម្មករនិយោជិតដែលបានធ្វើការនៅក្នុងរោងចក្រ សហគ្រាស គ្រឹះស្ថាន ណាមួយលើសពីមួយឆ្នាំឡើងទៅ ត្រូវទទួលបានប្រាក់រង្វាន់អតីតភាពការងារ ដូចមាននៅក្នុងតារាង ខាងក្រោមនេះ ៖*

| *អតីតភាពការងារ គិតជាឆ្នាំ* | *1* | *2* | *3* | *4* | *5* | *6* | *7* | *8* | *9* | *10* | *11* |
|---|---|---|---|---|---|---|---|---|---|---|---|
| *ចំនួនទឹកប្រាក់ទទួលបាន ក្នុងមួយខែ គិតជាដុល្លារអាមេរិក* | *0* | *2* | *3* | *4* | *5* | *6* | *7* | *8* | *9* | *10* | *11* |

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ២៥៥/១៣-ឰ យៀន បានបកស្រាយនៅក្នុងហេតុផលចំណុចវិវាទទី១ ថា ៖ *"...ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញទៀតថា គោលបំណងការផ្តល់ប្រាក់រង្វាន់អតីតភាពការងារនេះ គឺមិនមែនត្រឹមតែផ្តល់ជូនកម្មករនិយោជិតដោយគ្រាន់តែគិតពីរយៈពេលនៃសេវាកម្មការងារ ដែលកម្មករនិយោជិតបានធ្វើការជូននិយោជកប៉ុណ្ណោះទេ ប៉ុន្តែក៏ដើម្បីផ្តល់ជូនកម្មករនិយោជិតដែលបានមានបទពិសោធន៍ការងារ ការខិតខំប្រឹងប្រែង និងភាពស្មោះត្រង់ ក្នុងការបំពេញការងារជូនដល់និយោជកទៅតាមរយៈពេលដែលពួកគាត់បានបំពេញការងារជូននិយោជកផងដែរ ពីព្រោះកម្មករនិយោជិតដែលមានអតីតភាពការងារកាន់តែច្រើន គឺនឹងប្រើប្រាស់កាន់តែល្អប្រសើរឡើងនូវគុណសម្បត្តិ ដូចបានរៀបរាប់មកខាងលើ ទៅតាមរយៈពេលនៃអតីតភាពការងាររបស់ខ្លួន ក្នុងការបំពេញការងារជូននិយោជក។..."*។

ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្រប និងទទួលយកការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងខាងលើដែរ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការកំណត់ផ្តល់ប្រាក់រង្វាន់អតីតភាពការងារ ដល់កម្មករនិយោជិត នៃសេចក្តីជូនដំណឹងលេខ ០៤១/១១ កប/សជណ ក៏ផ្សាភ្ជាប់ជាមួយនឹងរយៈពេលដែលកម្មករនិយោជិតបានទទួលនូវបទពិសោធន៍ការងារ ការខិតខំប្រឹងប្រែង និងភាពស្មោះត្រង់ ក្នុងការបំពេញការងារជូនដល់និយោជក។

យោងតាមការបកស្រាយមាត្រា ១០២ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ប្រាក់រង្វាន់អតីតភាពការងារក៏ត្រូវបានចាត់ទុកថា ជាថ្លៃឈ្នួលការងារបន្ថែមដែលនិយោជកត្រូវផ្តល់ឱ្យកម្មករនិយោជិត ដែលមានអតីតភាពដូចបានកំណត់នៅក្នុងសេចក្តីជូនដំណឹងខាងលើ ដើម្បីជាថ្នូរនឹងការប្រើប្រាស់នូវបទពិសោធន៍ការងារ, ការខិតខំប្រឹងប្រែង និងភាពស្មោះត្រង់ ទៅតាមកម្រិតអតីតភាពការងាររបស់ខ្លួន ក្នុងការបំពេញការងារជូននិយោជក។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ប្រាក់រង្វាន់អតីតភាពការងារនេះ ក៏ត្រូវចាត់ទុកជាចំណែកមួយបន្ថែមនៃប្រាក់ឈ្នួលពេលធ្វើការធម្មតា ដែលកម្មករនិយោជិតមានអតីតភាព ដូចមានកំណត់ក្នុងសេចក្តីជូនដំណឹងខាងលើ ត្រូវទទួលបានពីនិយោជក ក្រៅពីប្រាក់ឈ្នួលគោលរបស់គាត់។

តាមរយៈអង្គហេតុ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា និយោជកយកតែប្រាក់ឈ្នួលគោល ដើម្បីធ្វើជាមូលដ្ឋានក្នុងការគណនាប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោងជូនកម្មករនិយោជិតតែប៉ុណ្ណោះ ដោយមិនបញ្ចូលប្រាក់រង្វាន់អតីតភាពការងារក្នុងការគណនានេះទេ។ ហេតុនេះ យោងតាមការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញា

កណ្តាលយល់ឃើញថា និយោជកមានកាតព្វកិច្ចបញ្ចូលប្រាក់រង្វាន់អតីតភាពការងារជាមួយនឹងប្រាក់ឈ្នួលគោល ដើម្បីធ្វើជាមូលដ្ឋានក្នុងការគណនាប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោងជូនកម្មករនិយោជិត។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បង្គាប់ឱ្យនិយោជកបញ្ចូលប្រាក់រង្វាន់អតីតភាពការងារជាមួយនឹងប្រាក់ឈ្នួលគោល ដើម្បីធ្វើជាមូលដ្ឋានក្នុងការគណនាប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោងជូនកម្មករនិយោជិត។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សា-អាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ១ ៖**

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តចំនួន ២០ ដុល្លារអាមេរិក ក្នុងមួយខែ នៅពេលកម្មករនិយោជិតដេរ និងកាត់ព្រុយ គ្រប់ចំនួនកំណត់ និងផ្តល់ប្រាក់រង្វាន់ចំនួន ២០ ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់ការបន្ថែមការងារកាត់ព្រុយ ជូនកម្មករនិយោជិតផ្នែកដេរ។

**ចំណុចវិវាទទី ២ ៖**

- បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ចំនួន ២០០០ រៀល ក្នុងមួយម៉ោង។

**ចំណុចវិវាទទី ៣ ៖**

- បង្គាប់ឱ្យនិយោជកបញ្ចូលប្រាក់រង្វាន់អតីតភាពការងារ ជាមួយប្រាក់ឈ្នួលគោល សម្រាប់ជាមូលដ្ឋានក្នុងការគណនាប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោងជូនកម្មករនិយោជិត។

**ប្រភេទនៃសេចក្តីបង្គាប់៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា ៖ ----------------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **ឡូន ស៊ីផាន់**

ហត្ថលេខា ៖----------------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ិនឈា**

ហត្ថលេខា ៖ ------------------------------------

**ឧបសម្ព័ន្ធនៃសេចក្តីបង្គាប់លេខ ០៨៦/១៩-ឃែនធើរេន អឺតែរឺល (ខេមបូឌា)**

## យោបល់ជំទាស់ទៅលើសេចក្តីសម្រេច
## នៃសំណុំរឿង ០៨៦/១៩-ឃែនធើរេន អឺតែរឺល (ខេមបូឌា)
## ដោយអាជ្ញាកណ្តាល អ៊ីង សុទ្ធី ដែលជ្រើសរើសដោយភាគីនិយោជក

ប្រការ ៣៧ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ របស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ បានចែងថា *"ក្រុមអាជ្ញាកណ្តាលត្រូវកត់ត្រាពល់សេចក្តីម្រេចរបស់ខ្លួនក្នុងសេចក្តីបង្គាប់មួយ ដែលត្រូវចុះហត្ថលេខារបស់អាជ្ញាកណ្តាលទាំង ០៣ រូប។ ក្នុងករណីដែលអាជ្ញាកណ្តាលណាម្នាក់មិនឯកភាពនឹងសេចក្តីសម្រេចតាមមតិភាគច្រើននោះ គាត់អាចកត់ត្រាយោបល់ជំទាស់របស់គាត់ធ្វើជាឧបសម្ព័ន្ធមួយ ក្នុងសេចក្តីបង្គាប់នោះ "*។

យោងតាមប្រការនេះ ខ្ញុំអាជ្ញាកណ្តាល **អ៊ីង សុទ្ធី** សូមផ្តល់នូវយោបល់ជំទាស់ទៅនឹងហេតុផលនៃសេចក្តីសម្រេចនៃសេចក្តីបង្គាប់លេខ **០៨៦/១៩-ឃែនធើរេន អឺតែរឺល (ខេមបូឌា)** នៅក្នុងចំណុច **វិវាទទី៣** ដែលបង្គាប់ឱ្យនិយោជកបញ្ចូលប្រាក់រង្វាន់អតីតភាពការងារ ជាមួយប្រាក់ឈ្នួលគោល សម្រាប់ជាមូលដ្ឋានក្នុងការគណនាប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោង ជូនកម្មករនិយោជិត។

ខ្ញុំសូមបញ្ជាក់អំពីមូលហេតុនៃការជំទាស់ ដូចមានក្នុងសេចក្តីអត្ថាធិប្បាយខាងក្រោមនេះ ៖

**ប្រាក់ឈ្នួលគោល** ៖ គឺគេបង្កើតឡើង ក្នុងគោលបំណង ២ យ៉ាង គឺ ៖

ទី១- សម្រាប់ធានាតាមផ្លូវច្បាប់ កុំឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលគោលនៅក្រោមការកំណត់នេះ។

ទី២- សម្រាប់យកជាមូលដ្ឋាន ក្នុងការគណនាប្រាក់ឈ្នួលផ្សេងៗ ដែលនិយោជកត្រូវផ្តល់ឱ្យកម្មករនិយោជិត។

ប្រាក់រង្វាន់អតីតភាពការងារ ៖ ជាប្រាក់រង្វាន់លើកទឹកចិត្តដល់កម្មករនិយោជិត ឱ្យធ្វើការនៅកន្លែងនេះឱ្យបានយូរអង្វែង។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលបកស្រាយនៅក្នុងហេតុផលនៃសេចក្តីសម្រេច ហើយបង្គាប់ឱ្យនិយោជកយកប្រាក់ឈ្នួលគោល បូកបញ្ចូលប្រាក់រង្វាន់អតីតភាពការងារ ដើម្បីធ្វើជាមូលដ្ឋានគណនាប្រាក់ បន្ថែមម៉ោង គឺមិនមានមូលដ្ឋានផ្លូវច្បាប់ទេ គឺផ្អែកលើគោលការណ៍សមធម៌។

ដូច្នេះ ដើម្បីឱ្យសមធម៌ ដែលអាចឱ្យនិយោជកទទួលយកបាន គឺនៅពេលដែលកម្មករនិយោជិតមិនមកធ្វើការក៏ត្រូវយកមូលដ្ឋានខាងលើមកអនុវត្ត គឺការកាត់ប្រាក់ឈ្នួល ត្រូវយកប្រាក់ឈ្នួលគោលបូកបញ្ចូលប្រាក់រង្វាន់អតីតភាពការងារ ដើម្បីធ្វើជាមូលដ្ឋានក្នុងការកាត់ប្រាក់ឈ្នួលដែរ។

ថ្ងៃពុធ ៤កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩
ហត្ថលេខារបស់អាជ្ញាកណ្តាល

**អ៊ីង សុទ្ធី**